**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៣ ❖ ៤

**ក្រសួងអប់រំ យុវជន និង កីឡា**
**លេខ : ៤១០ អយក.ប្រក**

# ប្រកាស

ស្តីពីការផ្តាច់សាលាបឋមសិក្សា **ឧបសម្ព័ន្ធ ផ្សៀងរាំ**

មកជាសាលាបឋមសិក្សាពេញលក្ខណៈ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានពិនិត្យលិខិតលេខ ១០៦ អយក.បម ចុះថ្ងៃទី ១៩ ខែ ២ ឆ្នាំ ២០០២ របស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ស្វាយរៀង

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## <u>សម្រេច</u>

**<u>ប្រការ១</u>** :- ផ្តាច់សាលាបឋមសិក្សាឧបសម្ព័ន្ធ **ផ្សៀងរាំ** ពីសាលាបឋមសិក្សា **ហ៊ុន សែនសំបួរ** ដែលមានទីតាំងស្ថិតនៅភូមិ **ខ្នុំ** ឃុំ **សំបួរ** ស្រុក **រមាសហែក** ខេត្ត **ស្វាយរៀង** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**<u>ប្រការ២</u>** :- សាលាបឋមសិក្សា **ផ្សៀងរាំ** ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**<u>ប្រការ៣</u>** :- នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**<u>ប្រការ៤</u>** :- បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**<u>ប្រការ៥</u>** :- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ស្វាយរៀង** ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក **រមាសហែក** នាយកសាលាបឋមសិក្សា **ផ្សៀងរាំ** នាយកសាលាបឋមសិក្សា **ហ៊ុន សែនសំបួរ** មានភារកិច្ច អនុវត្តប្រកាសនេះ ។

ភ្នំពេញ .ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០២

ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

រដ្ឋលេខាធិការ

**អ៊ឹម.សិទ្ធី**

**<u>កន្លែងទទួល</u> :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សាលាខេត្ត ស្វាយរៀង

" <u>ដើម្បីជូនជ្រាបជាពតិមាន</u> "

- ដូចប្រការ ៥
- កាលប្បវត្តិ
- ឯកសារ នា -ប.ម